# គំនិតទូទៅខ្លីៗរបស់មុខវិជ្ជា

១. គោលដៅសំខាន់សំរាប់មុខវិជ្ជានេះ

គ្រីស្តបរិស័ទចាំបាច់ត្រូវប្រើកំហឹងរបស់ពួកគេដើម្បីបង្ហាញសេចក្តីស្រលាញ់របស់ពួកគេដល់ព្រះជាម្ចាស់ នៅក្នុងផ្លូវមួយប្រកបទៅដោយអត្ថន័យនៅក្នុងជីវិតរបស់នៅប្រចាំថ្ងៃរបស់ពួកគេ ។

២. ខគម្ពីរសំខាន់សំរាប់សប្តាហ៏ : អេភេសូ ៤:២៦-២៧

ប្រសិនបើបងប្អូន សូមប្រយត្ន័កុំប្រព្រឹត្តអំពើបាប កុំទុកកំហឹងរហូតដល់ថ្ងៃលិចនោះឡើយ ។ កុំហុចឱកាសអោយមារមកល្បួងបងប្អូន ។

៣. យោងតាមឯកសាររបស់សិស្ស

សូមពន្យល់ថាមានវិធីពីរយ៉ាងដើម្បីចាប់ផ្តើមបង្រៀនមុខវិជ្ជានេះ ។ ខាងក្រោមនេះគឺជាចំនុចចាប់ផ្តើមខុសគ្នាទាំងពីរនេះ ។

១. ផ្លូវរបស់ព្រះជាម្ចាស់សំរាប់គ្រីស្តបរិស័ទប្រើកំហឹងរបស់ពួកគេ

២. ផ្លូវនៃការប្រើកំហឹងរបស់ខ្ញុំបច្ចុប្បន្ន

យើងនឹងចាប់ផ្តើមបង្រៀនមុខវិជ្ជានេះពីជំរើសទី ២ ទៅ-ផ្លូវនៃការប្រើកំហឹងរបស់ខ្ញុំបច្ចុប្បន្ន ។ នេះគឺជាវិធីដ៏មានសារៈសំខាន់ជាងដើម្បីចូលទៅជិតបញ្ហា ដោយសារតែយើងមានចំនុចចាប់ផ្តើមដ៏ច្បាស់លាស់ ។

៤. ទទួលស្គាល់កំហឹង

យើងខ្ញុំសូមផ្តល់ជាយោបល់ថា ឧទាហរណ៏មួយនៅក្នុងចំណោមឧទាហរណ៏ជាច្រើនដែលអាចត្រូវបានប្រើយ៉ាងស្រួលនៅក្នុងមុខវិជ្ជានេះទាំងមូលគឺ បញ្ហាដែលយើងមាន នៅពេលដែលនរណាម្នាក់បានបង្ហាញការមិនគោរពចំពោះយើង ។

មេរៀន ទី ១ : តើអ្វីធ្វើអោយខ្ញុំខឹង

- មនុស្សម្នាក់នេះមិនគោរពខ្ញុំទេ

តើខ្ញុំបង្ហាញកំហឹងរបស់ខ្ញុំដោយរបៀបណា?

- ការឆ្លើយតបរបស់ខ្ញុំ

តើហេតុអ្វីបានជាខ្ញុំខឹង?

- គេរំលោភសិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំ : " ខ្ញុំមានសិទ្ធិអោយគេគោរព ។ "

# មេរៀនទី ១ :

# ថ្មីៗនេះតើខ្ញុំប្រើកំហឹងរបស់ខ្ញុំដោយរបៀបណា?

## ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ខ្ញុំអាចប្រើកំហឹងរបស់ខ្ញុំដើម្បីទទួលស្គាល់សិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំ ។

## ២. ខ គម្ពីរសំខាន់ : យ៉ាកុប ១:២០

ដ្បិតអ្នកមានកំហឹង ពុំអាចធ្វើអ្វីស្របតាមសេចក្តីសុចរិតរបស់ព្រះជាម្ចាស់បានឡើយ ។

## ៣. យោងតាមឯកសាររបស់សិស្ស

នៅទំព័រ ទី ២-៤ ក្នុងសៀវភៅណែនាំរបស់សិស្សស៊ីគ្នាជាមួយនឹងមេរៀននេះ ។ គំរោង ទី ១ នៅក្នុងការណែនាំការសិក្សានឹងត្រូវបានប្រើផងដែរជាមួយនឹងមេរៀននេះ ។

## ៤. ការទទួលស្គាល់កំហឹង

ចំណាយពេលវេលាច្រើននៅក្នុងថ្នាក់ពិភាក្សាគំរោង ទី ១ នៅក្នុងសៀវភៅណែនាំការសិក្សា ។ ពួកគេត្រូវបំពេញអោយហើយនូវគំរោង ទី ១ មុននឹងមេរៀនទី ១ ចាប់ផ្តើម ។

- សូមធ្វើអោយប្រាកដថា ពួកគេមិនភាន់ច្រឡំចំលើយរបស់ពួកគេសំរាប់សំនួរ ទី ១ និង សំនួរ ទី ៣ ។
- សូមអោយសិស្សម្នាក់ៗចែកចាយឧទាហរណ៍យ៉ាងហោចណាស់អោយបាន ១ ពីគំរោង នេះ ។
- សូមធ្វើអោយប្រាកដថា ពួកគេយល់ដឹង និង មើលឃើញយ៉ាងច្បាស់លាស់នូវភាពខុសគ្នារវាងបញ្ហាទាំងបី ដែលត្រូវបានលើកឡើងនៅក្នុងសំនួរក្នុងគំរោងនេះ ។

## ៥. ខឹង

បន្ទាប់ពីពិភាក្សាគំរោង ទី ១សំរាប់រយៈពេល ២០ នាទី មក សូមផ្តោតទៅលើសំនួរ ទី ៣ ម្តងទៀត " តើហេតុអ្វីបានជាខ្ញុំខឹង? " សូមពិភាក្សាថាតើហេតុអ្វីបានជាស្ថានភាពទាំងនេះធ្វើអោយពួកគេខឹង ។ នេះគឺជាវិធីមួយក្នុងការបង្ហាញចំនុចនេះ ។

ហេតុអ្វីបានជាខ្ញុំខឹង?

១. " អ្នកបានធ្វើអ្វីមួយខុស! "

- " ហើយខ្ញុំមិនចូលចិត្តការនោះទេ!

២. " តើខ្ញុំដឹងដោយរបៀបណាថា អ្នកបានធ្វើអ្វីមួយខុស ? "

- " ពីព្រោះខ្ញុំមានច្បាប់ របស់ខ្ញុំ! "

៣. " អ្នកបានធ្វើខុសនឹងច្បាប់របស់ខ្ញុំមួយ! "

- " ហើយខ្ញុំមិនចូលចិត្តការនោះទេ!

ពិភាក្សានិយមន័យនៃ " ច្បាប់របស់ខ្ញុំ " ។ យើងអាចហៅបានថា " សិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំ " ។ ច្បាប់ដែលបង្ហាញបង្កើតឡើងសំរាប់ខ្លួនឯងផ្ទាល់ដែលខ្ញុំរំពឹងអោយអ្នកដទៃគោរព ។

៦. សិទ្ធិផ្ទាល់ខ្លួន

ប្រើឧទាហរណ៍របស់ពួកគេពីគំរោង ទី ១ និង ត្រឡប់ទៅពិភាក្សាសិទ្ធិផ្ទាល់ខ្លួនដែលអាចពិភាក្សាបាននៅក្នុងស្ថានភាពនិមួយៗ ។ សូមពន្យល់ថា នេះគឺជាអ្វីដែលយើងនឹងធ្វើនៅលើគំរោង ទី ៣សំរាប់រៀនពេលក្រោយ ។

៧. ហេតុផលក្នុងការទទួលស្គាល់សិទ្ធិផ្ទាល់ខ្លួន

មេរៀន ទី ១

កកដថសលដកកកដលថសា

អត្ថបទគម្ពីរអំពី កំហឹង

សុភាសិត ១២-១៦

សុភាសិត ១៤:១៧

សុភាសិត ១៤:២៩

សុភាសិត ១៥:១

សុភាសិត ១៦:៣២

សុភាសិត ១៩:១១

សុភាសិត ១៩:១៩

សុភាសិត ២១:១៤

សុភាសិត ២២:២៤,២៥

ម៉ាថាយ ៥:២១-២២

ម៉ាកុស ៣:១-៥

អេភេសូ ៤:២៦-២៧

អេភេសូ ៤:៣១

កូឡូស ៣:៨

កូឡូស ៣:១២

២ ធីម៉ូថេ ២:១៦-១៧

យ៉ាកុប ១:១៩-២១

មេរៀន ទី ២

លះបង់សិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំ

## ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ក្នុងនាមជាគ្រីស្តបរិស័ទ ខ្ញុំចាំបាច់ត្រូវតែលះបង់សិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំទៅព្រះជាម្ចាស់ ។

## ២. ខ គម្ពីរសំខាន់ : ២ កូរិនថូស ៩:៧

ញដសថសដលកថកសលដលលល។។។។។។។។។។។។។។ដ្បិតអ្នកមានកំហឹង

ពុំអាចធ្វើអ្វីស្របតាមសេចក្តីសុចរិតរបស់ព្រះជាម្ចាស់បានឡើយ ។

## ៣. យោងតាមឯកសាររបស់សិស្ស

នៅទំព័រ ទី ៤-៧ ក្នុងសៀវភៅណែនាំរបស់សិស្សស៊ីគ្នាជាមួយនឹងមេរៀននេះ ។ គំរោង ទី ២ និង គំរោង ទី ៣ នៅក្នុងការណែនាំការសិក្សានឹងត្រូវបានប្រើផងដែរជាមួយនឹងមេរៀននេះ ។

## ៤. ព្រះជាម្ចាស់ និង សិទ្ធិផ្ទាល់ខ្លួន

យើងនឹងបង្រៀនបញ្ហាសំខាន់ៗពីរនៅក្នុងមេរៀននេះ

ក. តើហេតុអ្វីបានជាខ្ញុំគួរតែផ្តល់សិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំថ្វាយដល់ព្រះជាម្ចាស់?

ខ. តើខ្ញុំអាចផ្តល់សិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំថ្វាយដល់ព្រះជាម្ចាស់ដោយរបៀបណា?

៥. និយមន័យនៃសិទ្ធិផ្ទាល់ខ្លួន

សូមចំណាយពេលពី ៥-១០ នាទី ដំបូងដើម្បីរំលឹកឡើងវិញនូវប្រធានបទនៃសិទ្ធិផ្ទាល់ខ្លួន ។ រំលឹកនិយមន័យដែលយើងបានផ្តល់ជូននូវពាក្យថា សិទ្ធិផ្ទាល់ខ្លួន ។ សូមអោយសិស្សចែកចាយនូវឧទាហរណ៍នៃសិទ្ធិផ្ទាល់ខ្លួនពីគំរោង ទី ៣ ។

៦. ថ្វាយដល់ព្រះជាម្ចាស់

លើកក្រោយ ពិភាក្សាសេចក្តីពិតនៃព្រះគម្ពីរ និង ខគម្ពីរសំខាន់ៗ

៧. តើហេតុអ្វីបានជាយើងគួរតែផ្តល់សិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំថ្វាយដល់ព្រះជាម្ចាស់?

សូមចំណាយពេល ៥-១០ នាទីពិភាក្សា តើហេតុអ្វីបានជាខ្ញុំគួរតែផ្តល់សិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំថ្វាយដល់ព្រះជាម្ចាស់ ។ សូមមើលទំព័រ ទី ៥ នៅក្នុងសៀវភៅណែនាំរបស់សិស្សសំរាប់ពត៌មានបន្ថែម ។ សូមធ្វើអោយប្រាកដថា ពួកគេយល់ដឹងយ៉ាងច្បាស់នូវបញ្ហាទាំងពីរនេះ:

១. ដោយសារតែខ្ញុំជាគ្រីស្តបរិស័ទ ខ្ញុំគួរតែថ្វាយសិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំដល់ព្រះជាម្ចាស់ ។ ខ្ញុំគួរតែជ្រើសរើសធ្វើដូច្នេះ ដោយសារតែទ្រង់គឺជាអ្នកដឹកនាំជីវិតរបស់ខ្ញុំ ។ (១ កូរិនថូស ៦:១៩-២០)

២. ដោយសារតែខ្ញុំចង់បង្ហាញសេចក្តីស្រលាញ់របស់ខ្ញុំថ្វាយដល់ព្រះជាម្ចាស់ ។

៨. របៀបថ្វាយសិទ្ធិផ្ទាល់ខ្លួនដល់ព្រះជាម្ចាស់

សូមចំណាយពេលវេលាដ៏ច្រើនរបស់ថ្នាក់រៀននូវថ្ងៃនេះដោយពិភាក្សាពីរបៀបថ្វាយសិទ្ធិផ្ទាល់ខ្លួនដល់ព្រះជាម្ចាស់ ។ សូមពិនិត្យមើល សៀវភៅណែនាំរបស់សិស្ស នូវទំព័រ ទី ៦-៧ សំរាប់ការពន្យល់ចំនុច ទី ៤ " តើខ្ញុំអាចផ្តល់សិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំថ្វាយដល់ព្រះជាម្ចាស់ដោយរបៀបណា? " សូមប្រាប់ពួកគេនូវផ្នែកពិបាកបំផុតគឺរៀនដើម្បីឆ្លើយតបទៅតាមផ្លូវរបស់ព្រះជាម្ចាស់ ។

៩. សូមបិទដោយការអធិស្ឋាន

១០. កិច្ចការត្រូវធ្វើ

ក. នៅបញ្ចប់ថ្នាក់រៀន សូមផ្តល់សំនួរខ្លីៗនៅលើ អេភេសូ ៤:២៦-២៧

ខ. សូមដាក់ពិន្ទុគំរោង ទី ២ និង គំរោង ទី ៣

# មេរៀនទី ៣ :

# ការឆ្លើយតបទៅតាមផ្លូវរបស់ព្រះជាម្ចាស់

## ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ខ្ញុំចាំបាច់ត្រូវតែរកអោយឃើញនូវការឆ្លើយតបទៅតាមផ្លូវរបស់ព្រះជាម្ចាស់ នៅពេលដែលនរណាម្នាក់រំលោភអតីតសិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំមួយ ។

## ២. ខ គម្ពីរសំខាន់ : យ៉ាកុប ១:១៩

.........

## ៣. យោងតាមឯកសាររបស់សិស្ស

នៅទំព័រ ទី ៥ ក្នុងសៀវភៅណែនាំរបស់សិស្សស៊ីគ្នាជាមួយនឹងមេរៀននេះ ។

## ៤. របៀបឆ្លើយតប

ប្រធានបទដ៏សំខាន់ដែលយើងចង់បង្រៀនថ្ងៃនេះគឺ ថាតើខ្ញុំគួរតែឆ្លើយតបយ៉ាងដូចម្តេចបន្ទាប់ពីខ្ញុំថ្វាយសិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំដល់ព្រះជាម្ចាស់?

៥. រំលឹកឡើងវិញ

រំលឹកយ៉ាងលឿននូវជំហានពីរបៀបថ្វាយសិទ្ធិផ្ទាល់ខ្លួនរបស់អ្នកដល់ព្រះជាម្ចាស់ ។ សូមមើលចំនុច ទី ៤ នៅលើទំព័រ ទី ៦-៧ នៅក្នុងសៀវភៅណែនាំរបស់សិស្ស ។

៦. ការផ្លាស់ប្តូរការឆ្លើយតបគឺពិបាក

សូមពន្យល់ម្តងទៀតថា ផ្នែកដ៏ងាយស្រួលនៃដំណើរការផ្លាស់ប្តូរនេះគឺថ្វាយសិទ្ធិផ្ទាល់ខ្លួនដល់ព្រះជាម្ចាស់ ។ ផ្នែកដ៏ពិបាកបំផុតគឺរកអោយឃើញនូវផ្លូវថ្មីនៃការឆ្លើយតបនៅពេលមនុស្សរំលោទអតីតសិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំ ។

៧. ផ្លូវថ្មីក្នុងការឆ្លើយតប

ពិភាក្សាតារាងពីផ្លូវថ្មីនៃការឆ្លើយតប ។ សូមមើលតារាងដែលមានចំណងជើងថា " តើខ្ញុំគួរតែឆ្លើយតបយ៉ាងដូចម្តេចបន្ទាប់ពីខ្ញុំថ្វាយសិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំដល់ព្រះជាម្ចាស់? ពតិមានបន្ថែមដែលទាក់ទងទៅនឹងកិច្ចការនេះមាននៅលើទំព័រ ទី ៧-៩ ក្នុងសៀវភៅណែនាំរបស់សិស្ស ។

៨. បញ្ញត្តិរបស់ព្រះជាម្ចាស់

សូមចំណាយពេលវេលាច្រើនពិភាក្សាចំនុចទី ១ នៅលើតារាង " ស្វែងរកបញ្ញត្តិរបស់ព្រះជាម្ចាស់ដែលប្រាប់ខ្ញុំពីរបៀបឆ្លើយតបនៅពេលដែលនរណាម្នាក់រំលោភអតីតសិទ្ធិផ្ទាល់ខ្លួន ។ " អ្នកអាចចំណាយពេលវេលាដ៏មានប្រយោជន៍របស់អ្នកពិភាក្សានូវអ្វីដែលព្រះគ្រីស្ទ បាននិយាយនៅក្នុងអត្ថបទខគម្ពីរទាំងពីរនេះ ។

ក. លូកា ៦:២៧-៣៨

ខ. ម៉ាថាយ ៦:២៥-៣៤

៩. កំហឹងជា.............។

ចំណាយពេលខ្លះពិភាក្សា ចំនុចទី ២ : " ប្រើកំហឹងសំរាប់នាឡិការោរ៍របស់ខ្ញុំ ។ "

១០. កិច្ចការត្រូវធ្វើ

នៅបញ្ចប់ថ្នាក់ សូមផ្តល់សំនួរខ្លីៗនោលើ យ៉ាកុប ១:១៩-២០

មេរៀន ទី ៣

កំណត់ចំណាំ...........។

តារាង

តើខ្ញុំគួរតែឆ្លើយតបយ៉ាងដូចម្តេចបន្ទាប់ពីខ្ញុំថ្វាយសិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំដល់ព្រះជាម្ចាស់?

១. រកអោយឃើញបញ្ញត្តិរបស់ព្រះជាម្ចាស់ដែលប្រាប់យើងពីរបៀបឆ្លើយតបនៅពេលនរណាម្នាក់រំលោភអតីតសិទ្ធិផ្ទាល់ខ្លួន ។

លូកា ៦:២៧-៣៨

២. ប្រើកំហឹងសំរាប់ជានាឡិការោរ៍

៣. រៀនបង្កើតគុណភាពវិជ្ជមាននៅខាងក្នុងដើម្បីប្រើនៅពេលធ្វើការឆ្លើយតប

កូឡុស ៣:១២-១៥

១ កូរិនថូស ១៣:៤-៨

មេរៀន ទី ៤

គុណភាពវិជ្ជមានខាងក្នុង

## ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ខ្ញុំចាំបាច់ត្រូវតែបង្កើតគុណភាពវិជ្ជមាននៅក្នុងដើម្បីប្រើនៅពេលធ្វើការឆ្លើយតបចំពោះស្ថានភាពដែលអតីតសិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំត្រូវបានគេរំលោភ ។

## ២. ខ គម្ពីរសំខាន់ : កូឡូស ៣:១២

...........................

## ៣. យោងតាមឯកសាររបស់សិស្ស

នៅទំព័រ ទី ៦-៩ ក្នុងសៀវភៅណែនាំរបស់សិស្សស៊ីគ្នាជាមួយនឹងមេរៀននេះ ។ គំរោងទី ទ ៦នៅក្នុងសៀវភៅណែនាំការសិក្សានឹងត្រូវបានប្រើផងដែរនៅក្នុងមេរៀននេះ ។

## ៤. អាកប្បកិរិយាវិជ្ជមាននៅខាងក្នុង

ប្រធានបទដ៏សំខាន់ដែលយើងចង់បង្រៀននៅក្នុងមេរៀននេះគឺពីរបៀបបង្កើតគុណភាពវិជ្ជមានខាងក្នុងដើម្បីប្រើនៅពេលដែលធ្វើការឆ្លើយតបចំពោះអ្នកដទៃ ។

៥. របៀបឆ្លើយតប

រំលឹកឡើងវិញនៅតារាងដែលមានចំណងជើងថា " តើខ្ញុំគួរតែឆ្លើយតបយ៉ាងដូចម្តេច បន្ទាប់ពីខ្ញុំថ្វាយសិទ្ធិផ្ទាល់ខ្លួនរបស់ខ្ញុំដល់ព្រះជាម្ចាស់ ។ "

៦. កំហឹងជាសញ្ញា ........។

សូមចំណាយពេលពីរបីនាទីដើម្បីពិភាក្សា លេខ ២ : " ការប្រើកំហឹងរបស់ខ្ញុំជានាឡិការោទិ៍ ។ "

៧. គុណភាពខាងក្នុងបំពេញកន្លែងទំនេរ

សូមចំណាយពេល ២៥-៣០ នាទី ដើម្បីពិភាក្សាលេខ ៣ នៅលើ ការបង្កើតគុណភាពវិជ្ជមានខាងក្នុង ។ សូមទំព័រ ទី ៨-៩ នៅក្នុងសៀវភៅណែនាំរបស់សិស្សសំរាប់ពតិមានបន្ថែមនៅលើកិច្ចការនេះ ។

៨. ការបង្កើតអាកប្បកិរិយាវិជ្ជមាន

គំរោង ទី ៦ ផុតកំណត់យកនៅថ្ងៃនេះ ដូច្នេះអ្នកអាចប្រើការនេះនៅក្នុងការពិភាក្សានៅក្នុងថ្នាក់ ។

៩. ធ្វើបញ្ជីគុណភាពខាងក្នុង

សូមអោយសិស្សអាន កូឡូស ៣:១២-១៥ ។ សូមអោយពួកគេបង្ហាញគុណភាពវិជ្ជមានខាងក្នុងដែលត្រូវ

បានបង្ហាញនៅក្នុងខគម្ពីរគម្ពីរទាំងនេះ ។ សូមសរសេរកិច្ចការទាំងនោះនៅលើការក្តារខៀន ។

១០. ការផ្លាស់ប្តូរគុណភាពខាងក្នុង

សូមយកស្ថានភាពពីគំរោង ទី ១ នៅលើ កំហឹង និង អោយពួកគេជ្រើសរើសគុណភាពវិជ្ជមានខាងក្នុងពីកូឡូស ៣:១២-១៥ នឹងជួយពួកគេជ្រើនបំផុតនៅក្នុងការឆ្លើយតបជាមួយនឹងបញ្ញត្តិរបស់ព្រះជាម្ចាស់ ។

១១. ការផ្លាស់ប្តូរគុណភាពវិជ្ជមានខាងក្នុងច្រើនថែមទៀត

សូមធ្វើកិច្ចការនេះជាមួយនឹងឧទាហរណ៍ជាច្រើន ។

១២. របៀបបង្ហាញគុណភាពវិជ្ជមានខាងក្នុង

ពិភាក្សាពីរបៀបអ្នកអាចបង្ហាញនូវគុណភាពវិជ្ជមានខាងក្នុងនិមួយៗទាំងនេះ ។ ឧទាហរណ៍ " តើខ្ញុំអាចធ្វើអ្វីដើម្បីបង្ហាញសប្បុរស? "

១៣. ការផ្លាស់ប្តូរការឆ្លើយតបដើម្បីយកជ័យជំនះលើកំហឹង

នៅក្នុងការពិភាក្សា សូមសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការឆ្លើយតបជាមួយនឹង :

ក. បញ្ញត្តិរបស់ព្រះជាម្ចាស់

ខ. គុណភាពវិជ្ជមាននៅខាងក្នុង

ខ្ញុំចាំបាច់ត្រូវតែមានកិច្ចការទាំងពីរនេះដើម្បីអោយខ្ញុំយកជ័យជំនះលើកំហឹងរបស់ខ្ញុំ ។

១៤. កិច្ចការត្រូវធ្វើ

ក. ដាក់ពិន្ទុ គំរោង ទី ៦

ខ. គំរោង ទី ៤ និង ទី ៥ ត្រូវបានបង្ហាញនូវតំលៃបន្ថែមទៀត ។ សូមផ្តល់ពិន្ទុនូវគំរោង ទាំងនេះ ប្រសិនបើសិស្សរបស់អ្នកបានបំពេញកិច្ចការទាំងនេះរួចហើយ ។